

ផ្ទាំងកញ្ចក់ថាមពលពន្លឺព្រះអាទិត្យ ដែលតំឡើងលើដំបូលផ្ទះនៅជនបទ

កម្មវិធីខាងលើផ្តល់នូវមូលនិធិក្នុងការជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញប្រសិទ្ធភាពថាមពល និងបច្ចេកវិទ្យាថាមពលស្អាតផ្សេងៗ។ គោលបំណងរបស់កម្មវិធីនេះគឺប្រយុទ្ធប្រឆាំង នឹងបំរែបំរួលអាកាសធាតុដោយផ្តល់នូវសេវាកម្មថាមពលប្រកបដោយចីរភាពដល់អ្នកត្រូវការថាមពល។

កម្មវិធីនេះផ្តែកលើការបើកអោយដាក់សំណើដែលបើកជាចំហរសំរាប់ស្ថាប័នសាធារណៈ និងឯកជន វិទ្យាស្ថានស្រាវជ្រាវ សាកលវិទ្យាល័យ និងអង្គការសង្គមស៊ីវិលនានា។ ការផ្តល់ឲ្យរបស់គំរោងកម្មវិធីនេះគឺ គ្រាន់តែផ្តល់នូវមូលនិធិមួយចំនួនទៅលើមូលនិធិផ្ទាល់របស់អ្នកលើកសំណើ។ សំណើសុំមូលនិធិសំរាប់កម្មវិធីនេះអាចធ្វើឡើងសំរាប់ការសិក្សាសមិទ្ធិលទ្ធភាពបឋមនិងសមិទ្ធិលទ្ធភាព ការសិក្សារុករកប្រភពធនធានថាមពល គំរោងបង្ហាញសាកល្បង និងគំរោងសិក្សាធ្វើការរៀបចំយុទ្ធសាស្ត្រ និងការអភិវឌ្ឍន៍គោលនយោបាយ។

ការផ្សព្វផ្សាយនិងការផ្លាស់ប្តូរពត៌មានតាមរយៈការបង្កើតសិក្ខាសាលាឡើង និងគេហទំព័រផ្សេងៗ គឺជាគោលបំណងមួយទៀតនៃការដំណើរការកម្មវិធីភាពជាដៃគូរក្នុងវិស័យថាមពល និងបរិស្ថាន នេះ។ កម្មវិធីភាពជា ដៃគូរក្នុងវិស័យថាមពលនិងបរិស្ថានតាមតំបន់ដំណើរការឡើងនៅក្នុងទ្វីបចំនួនបីដែលផ្តល់នូវឱកាសធ្វើការងាររួមគ្នាបានល្អនៅក្នុងវិស័យថាមពលនិងបរិស្ថាននេះ ។

ក្រសួងការបរទេស
របស់ប្រទេសហ្វាំងឡង់ដ៍

មូលនិធិអភិវឌ្ឍន៍នរ័ឌិក (NDF)

ពត៌មានបន្ថែមទៀតអំពីគំរោងភាពជាដៃគូរ និងការលើកសំណើទាំងឡាយមាននៅលើគេហទំព័រ

www.eepmekong.org,
www.findland.or.th/en
www.ndf.fi

ឬតាមរយៈការផ្ញើរសារទៅកាន់អ៊ីម៉ែល : eepmekong@eepmekong.org

# EEP

# គំរោងកម្មវិធីភាពជាដៃគូរក្នុងវិស័យថាមពល និងបរិស្ថាន





កម្មវិធីភាពជាដៃគូរក្នុងវិស័យថាមពលនិងបរិស្ថានដោយលើកកំពស់ក្នុងការ វិនិយោគថាមពលកកើតឡើងវិញប្រសិទ្ធភាពថាមពលនិងបច្ចេកវិទ្យាស្អាតនៅតាមបណ្តារប្រទេសដែលបានជ្រើសរើសដោយ ភ្ជាប់នូវគោលបំណងពីរយ៉ាងគឺ ក្នុងការផ្តល់ នូវសេវាកម្មថាមពល ដោយចីរភាពទៅដល់អ្នកក្រីក្រ និងការប្រយុទ្ធប្រឆាំងទៅនឹងបំរែបំរួលអាកាសធាតុ។

កម្មវិធីនេះត្រូវបានគេបង្កើតឡើងដើម្បីជួយសំរួលដល់ការអភិវឌ្ឍន៍នូវទស្សនៈនៃការបង្កើតថ្មីវិធីសាស្រ្ត និងគោលគំនិតទាំងឡាយទៅក្នុងគំរោងវិនិយោគ ថាមពលដែលអាចទទួលបានហិរញ្ញវត្ថុដែលនឹងនាំមក នូវអត្ថប្រយោជន៏សំរាប់បណ្តារប្រទេសដែលជាដៃគូរ។

វិធីសាស្រ្តនៃកម្មវិធីនេះគឺដើម្បីគាំទ្រដល់ការចូលរួមគ្រប់ស្ថាប័នទាំងស្ថាប័នរដ្ឋ ឯកជន ក្នុងស្រុកនិងក្នុងតំបន់។ សំរាប់កម្មវិធីក្នុងតំបន់ និងត្រូវផ្តល់នូវការផ្សព្វផ្សាយបទពិសោធន៏ដ៏ប្រសើរ និងការផ្ទេរនូវបច្ចេកវិទ្យា។

កម្មវិធីភាពជាដៃគូរក្នុងវិស័យថាមពលនិងបរិស្ថាន មានការផ្តល់ហិរញ្ញវត្ថុក្នុងជំរើសផ្សេងៗគ្នាក្នុងគំរោងការសិក្សាការសិក្សាអង្កេត និងក្នុងគំរោងបង្ហាញផ្សេងៗ ការអភិវឌ្ឍន៍ផ្ទៃផែនការគោលនយោបាយ ការផ្សព្វផ្សាយនិងការផ្លាស់ប្តូរពត៌-មាន។ គំរោងទាំងនោះនិងត្រូវកំណត់ឡើងតាមការអញ្ជើញអោយដាក់សំណើរសុំ។ សេដ្ឋកិច្ច សង្គម និងការទ្រទ្រង់បរិស្ថានការបង្កើនប្រាក់ ចំណូលនិងការងារ និងការសហាការក្នុងតំបន់គឺជាលក្ខខណ្ឌវិនិច្ឆ័យក្នុងចំណោមលក្ខខណ្ឌវិនិច្ឆ័យសំខាន់នៅក្នុងការជ្រើសរើសនូវសកម្មភាពគំរោង។ កម្មវិធីសិក្ខាសាលាក្នុងវិស័យកកើតថាមលគឺ ជាសកម្មភាពសំខាន់មួយផ្សេងទៀតក្នុងគំរោងនេះ។ សិក្ខាសាលាដែលបង្កើតឡើងជាតំបន់ដែលមានផ្នែកឯកជនរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលអង្គការស្ថាប័នផ្សេងៗ ចូលរួមនិងបំរើដល់ការផ្សព្វផ្សាយពត៌មាន និងការបង្កើននូវ នៃការយល់ដឹងនូវសក្តានុពលនៃប្រភពធនធានថាមពលកកើតឡើងវិញ។

តាមរយៈការផ្តួចផ្តើមឡើងដោយក្រសួងការបរទេសរបស់ប្រទេសហ្វាំងឡង់កម្មវិធីភាពជាដៃគូរក្នុងវិស័យថាមពល និងបរិស្ថានត្រូវបានគេកំពុងដំណើរការកម្មវិធី នេះក្នុងតំបន់ចំនួនបីរួចមកហើយនៅទ្វីបអាមេរិកកណ្តាលមួយទៀតនៅក្នុងតំបន់ភាគខាងត្បូង និងខាងកើតទ្វីបអាហ្វ្រិកនិងនៅក្នុងកំបន់ដងទន្លេមេគង្គ។ កម្មវិធីនេះផ្តល់នូវគ្រោងការដ៏អស្ចារ្យក្នុងការរួមគ្នាធ្វើការងារនិងក្នុងក្រប ខ័ណ្ឌកិច្ចសហប្រតិបត្តិការក្នុងតំបន់ខាងជើង-ខាងត្បូង និងខាងត្បូង-ខាងត្បូង ។




**គំរោងភាពជាដៃគូរក្នុងវិស័យថាមពល និងបរិស្ថាន**

គំរោងភាពជាដៃគូរក្នុងវិស័យថាមពល និងបរិស្ថានក្នុងតំបន់ទន្លេមេគង្គនឹងត្រូវបានទទូលការគាំទ្រក្នុងការប្រើប្រាស់យ៉ាងទូលំទូលាយនូវប្រភពថាមពលកកើតនៅក្នុងតំបន់ និងការប្រើប្រាស់ថាមពលដោយមានប្រសិទ្ធិភាព។ តំរូវការថាមពលនៅក្នុងតំបន់កើនឡើងយ៉ាងឆាប់រហ័សហើយស្របពេលជាមួយគ្នានេះដែរ បណ្តារប្រទេសទាំងឡាយក៏មានប្រភពថាមពលកកើតឡើងវិញយ៉ាងច្រើន។ ក្រុមហ៊ុនឯកជន សកលវិទ្យាល័យ មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវផ្សេងៗ និងបណ្តារអង្គភាព ឬស្ថាប័នសាធារណៈ និងឯកជនដ៏ទៃទៀតអាចដើរតួរយ៉ាងសំខាន់នៅក្នុងការប្រើប្រាស់នូវប្រភពថាមពលទាំងនោះឲ្យកាន់តែប្រសើរ ។

**ទីតាំងភូមិសាស្រ្ត**

ទីតាំងភូមិសាស្រ្តប្រទេសក្នុងកំបន់ទន្លេមេគង្គដែលអាចដាក់ពាក្យសុំរួមមាន ប្រទេសកម្ពុជា សាធារណៈរដ្ឋប្រជាមានិតឡាវ ប្រទេសថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម។ កម្មវិធីនេះគាំទ្រដល់គំរោងជាតិ និងកំបន់ព្រមទាំងលើកទឹកចិត្តដល់ភាពជាដៃគូរពាណិជ្ជកម្មរវាងបណ្តារប្រទេសជាដៃគូរក្នុងការអនុវត្តន៍ និងអង្គការផ្សេងៗ។

**អ្នកដែលមានសិទ្ធដាក់ពាក្យសុំសំរាប់កម្មវិធីនេះ**

អ្នកដែលមានសិទ្ធដាក់ពាក្យសុំសំរាប់កម្មវិធីនេះស្ថាប័ន សាធារណៈនិងឯកជន សាកលវិទ្យា-ល័យ មជ្ឈមណ្ឌលស្រាវជ្រាវ អង្គការមិនមែនរដ្ឋា-ភិបាលនានា សាលាក្រុង និងអង្គការឬស្ថាប័នដ៏ទៃផ្សេងទៀត ដែលមានសិទ្ធដាក់ពាក្យស្នើសុំមូលនិធិទាំងនេះ។ កិច្ចសហាការជាតំបន់ត្រូវបានគេនិយម។ ដើម្បីបង្កើននូវការផ្លាស់ប្តូរបច្ចេកវិទ្យាលើកទឹកចិត្តដល់កិច្ចសហាការរវាងបណ្តារប្រទេសផ្តល់ជំនួយ និងអ្នកអភិវឌ្ឍន៏គំរោងក្នុងស្រុក ។

**យន្តការនៃការផ្តល់មូលនិធិ**

កម្មវិធីភាពជាដៃគូរក្នុងវិស័យថាមពលនិងបរិស្ថាននៅក្នុងតំបន់ទន្លេមេគង្គ នឹងផ្តល់នូវទុនគ្រាប់ពូជសំរាប់គ្រប់សកម្មភាពថាមពលកកើតឡើងវិញបច្ចេកវិទ្យាថាមពលស្អាត និងប្រសិទ្ធភាពថាមពល។ គំរោងកម្មវិធីនេះគឺ ជាការផ្តល់បន្ថែមយ៉ាងសំខាន់ទៅលើមូលនិធិផ្ទាល់ខ្លួនរបស់អ្នកដាក់ពាក្យសុំ។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងស្ថានភាពខ្លះគំរោងអាចត្រូវបានទទួលមូលនិធិទាំង១០០ភាគរយក៏អាចមាន។គំរោងកម្មវិធីភាពជាគូរនឹងរៀបចំទទួលពាក្យសុំគំរោងក្នុងមួយឆ្នាំពីរលើក។ កម្មវិធីភាពជាដៃគូរក្នុងវិស័យថាមពលនិងបរិស្ថាននេះមានស្ថាប័សំរបសំរួលនៅក្នុងតំបន់ទន្លេព្រមេគង្គដែលមានទីតាំងស្ថិតនៅក្នុងទីបរិវេណ វិទ្យាស្ថាន បច្ចេកវិទ្យាអាស៊ាន ហៅកាត់ថា (AIT)។ ស្ថាប័ននេះទទួលខុសត្រូវរាល់ដំណើរការកម្មវិធីការងារប្រចាំថ្ងៃ។ សំរាប់ស្ថាប័នសំរបសំរួលរបស់ជាតិ នឹងជួយដល់អ្នកអភិវឌ្ឍន៍គំរោងទាំង-ឡាយនៅក្នុងបណ្តារប្រទេសជាដៃគូរ។ រាល់ការសំរេចចិត្តនានាត្រូវបានធ្វើឡើងដោយគណៈកម្មាធិការរបស់កម្មវិធីនេះដែលមានអ្នកតំណាងមកពីគ្រប់បណ្តារប្រទេសជាដៃគូរនិងអ្នកផ្តល់ជំនួយ។ មូលនិធិមានរយៈពេល ៣ឆ្នាំ ពីឆ្នាំ ២០០៩ ដល់ ២០១២ មានទឹកប្រាក់សរុប ៧,៩លានអឺរ៉ូ ដែលផ្តល់ ដោយក្រសួងការបរទេស របស់ប្រទេសហ្វាំងឡង់ និងមូលនិធិអភិវឌ្ឍន៍នរ៍ឌីក (NDF)។

**របៀបនៃការដាក់ពាក្យស្នើសុំ**

ស្ថាប័នសំរបសំរួលថ្នាក់ តំបន់គឺស្ថិតនៅក្នុងប្រទេសថៃនិងស្ថាប័នសំរបសំរួលថ្នាក់ ជាតិនៅក្នុងប្រទេសកម្ពុជា សាធារណៈរដ្ឋប្រជាមានិតឡាវ និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម និងជួយដល់អ្នកដែលមានបំណងចូលរួមសុំគំរោងពីរបៀបនៃការដាក់ពាក្យស្នើសុំសំរាប់កម្មវិធីនេះ។ ជាជំហ៊ានដំបូងគេនឹងវាយតំលៃលើទ្រង់ទ្រាយគំរោងដែលដាក់ស្នើសុំ។ ប្រសិនបើគេវាយតំល បានជោគជ័យអ្នកលើកគំរោង នឹងត្រូវបានគេស្នើឲ្យរៀបចំលំអិតលើសំណើសុំរបស់អ្នកដាក់ពាក្យសុំនោះ។ គោលគំនិតនៃគំរោងឬទំរង់សំណើមាននៅលើគេហទំព័រ www.eepmekong.org។